មជ្ឈមណ្ឌលឯកសារកម្ពុជា

គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)
សិក្ខាសាលាជាមួយគ្រូបង្រៀន-ក្រុមការងារស្តីពីការចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
ប្រាសាទព្រះវិហារ ថ្ងៃទី ២៤-២៦ ខែធ្នូ ឆ្នាំ២០១០

# អត្ថបទពិភាក្សាទី១

## យុត្តិធម៌បន្ទាប់បន្សំ ៖ ការរៀបចំយន្តការមួយសម្រាប់ការចងចាំ និងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា

*ព្រាងដោយ ឡូរ៉ា ហ្គូតវីន*
*ត្រួតពិនិត្យដោយ ម៉ារៀ ដេល ភីឡា ខាស្ទីលឡូ*
*កែសម្រួលដោយ ឆាំង យុ និង ចាយ៉ា វ៉ាមជី-ណូហ្គាឡែស*

### សេចក្តីផ្តើម

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានសម្រេចគោលដៅដ៏ជោគជ័យរបស់ខ្លួនក្នុងការកាត់ទោស«មេដឹកនាំជាន់ខ្ពស់»ខ្មែរក្រហម ។ យន្តការសម្រាប់យុត្តិធម៌អន្តរកាល ដែលផ្តោតលើតម្រូវការរបស់ប្រទេសកម្ពុជា បំពេញបំណងស្វែងរកយុត្តិធម៌ និងផ្តល់ជាសំណង ដែលប្រជាជនកម្ពុជាយល់ថាសមរម្យអាចក្លាយជាការជួយបំពេញបន្ថែមដល់តុលាការ ។ ជាញឹកញាប់ គណៈកម្មការស្វែងរកការពិតតែងតែត្រូវបានស្នើឲ្យបង្កើតឡើងដោយសារតែលក្ខណៈប្រែប្រួល និងលទ្ធភាពរបស់គណៈកម្មការនេះក្នុងការផ្តល់ជាដំណើរការទទួលខុសត្រូវដ៏សំខាន់តាមទំនៀមទម្លាប់វប្បធម៌ ។ ប្រព័ន្ធយុត្តិធម៌អន្តរកាលដ៏ជោគជ័យមួយនៅក្នុងប្រទេសកម្ពុជាត្រូវតែបំពេញទៅតាមលក្ខខ័ណ្ឌរបស់ប្រទេសកម្ពុជា និងបរិបទវប្បធម៌របស់ប្រជាជនកម្ពុជា ។

គណៈកម្មការស្វែងរកការពិតផ្តល់នូវឆន្ទៈបំពេញតម្រូវការរបស់សង្គមកម្ពុជា ។ យ៉ាងណាមិញដូចគ្នា នឹងទម្រង់យុត្តិធម៌អន្តរកាលផ្សេងទៀតដែរ គណៈកម្មការនេះនឹងជួបបញ្ហាប្រឈមនានា ។ រហូតមកដល់សព្វថ្ងៃនេះ គណៈកម្មការស្វែងរកការពិតស្ទើរតែទាំងអស់ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសដែលប្រតិបត្តិជំនឿគ្រិស្តសាសនា ។ ដើម្បីធ្វើឲ្យគណៈកម្មការស្វែងរកការពិតអាចឈានទៅរកការផ្សះផ្សា និងយុត្តិធម៌នៅក្នុងប្រទេសដែលមិនប្រតិបត្តិជំនឿគ្រិស្តសាសនាបាន លុះត្រាតែគណៈកម្មការនេះត្រូវតែរួមបញ្ចូលពុទ្ធសាសនិក និងអ្នកកាន់សាសនាអ៊ីស្លាមទៅក្នុងដំណើរការផ្សះផ្សានោះ ។ នៅ

ក្នុងប្រទេសកម្ពុជា គណៈកម្មការនិយាយពីការពិតដ៏ចម្រូងចម្រាស់នេះគួរតែឆ្លុះបញ្ចាំងឲ្យឃើញពីតម្លៃរបស់ពុទ្ធសាសនិក និងអ្នកកាន់សាសនាអ៊ីស្លាមដោយធ្វើការយកចិត្តទុកដាក់ចម្បងលើមេដឹកនាំសាសនា បំពេញតម្រូវការប្រជាជនកម្ពុជា និងបញ្ចូលសំណងជានិមិត្តរូប និងសំណងផ្សេងទៀតដែលអាចជួយអភិវឌ្ឍន៍តម្លៃរបស់សង្គមនេះបាន ។ ដើម្បីធ្វើជាគម្រូដ៏ល្អបំផុតនោះ អនុស្សរណៈនេះធ្វើការផ្តោតទៅលើតម្រូវការរបស់សង្គមកម្ពុជា ដូចដែលបានឃើញនៅក្នុងការស្ទាបស្ទង់មតិឆ្នាំ២០០៩ដែលស្រាវ-ជ្រាវ ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សនៅសកលវិទ្យាល័យ កាលីហ្វ័រញ៉ា រដ្ឋប៊ឺក្លេយ ដោយផ្តោតលើបទពិសោធន៍ដែលដកស្រង់ចេញពីគណៈកម្មាការស្វែងរកការពិតផ្សេងៗទៀតហើយទាញយកមតិឆ្លើយតបរបស់ប្រជាជនកម្ពុជាដែលមានចំពោះ អ.វ.ត.ក ។ ជាក់ស្តែង គណៈកម្មការនិយាយពីការពិតដ៏ជោគជ័យមួយអាចនឹងឈានទៅដល់ការទទួលខុសត្រូវ និងជួយប្រជាជនកម្ពុជារៀបរាប់ពីភាពអន្ធកាលនៅក្នុងរបបខ្មែរក្រហមដែលកើតមាននៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។

## គណៈកម្មការស្វែងរកការពិត

គណៈកម្មការស្វែងរកការពិតគឺជាយន្តការសម្រាប់យុត្តិធម៌អន្តរកាលមួយ ដែលមានអំណាចក្នុងការស៊ើបអង្កេតនិងដោះស្រាយអំពើហិង្សាលើសិទ្ធិមនុស្សកាលពីអតីតកាល ។ ការផ្តល់និយមន័យទៅលើពាក្យគណៈកម្មការស្វែងរកការពិតមានការលំបាកជាងប្រភេទនៃយុត្តិធម៌អន្តរកាលផ្សេងទៀត ដូចជាតុលាការអន្តរជាតិព្រោះថាគណៈកម្មការស្វែងរកការពិតនេះទោរទន់ទៅតាមសង្គមនិងកាលៈទេសៈរបស់សង្គមនីមួយៗ ។ លក្ខណៈសម្គាល់មួយចំនួននៃគណៈកម្មការស្វែងរកការពិតរួមមាន "គោលបំណងលាតត្រដាងអំពើហិង្សាដែលមានលក្ខណៈទូលំទូលាយធំជាជាងការសង្កត់ធ្ងន់លើព្រឹត្តិការណ៍ជាក់លាក់ណាមួយ.....ហើយការទទួលបាននូវអំណាចមួយចំនួនដោយធ្វើឲ្យមានការទទួលបានព័ត៌មាន និង សន្តិសុខ ។ ខុសពីតុលាការអន្តរជាតិ គណៈកម្មាការស្វែងរកការពិតមិនមែនជាក្រុមអ្នកធ្វើការកាត់ទោស ហើយមិនរៀបចំដំណើរការតុលាការដែលផ្តល់ជាលទ្ធផលជាការប្រកាសទោសនោះទេ ។ គោលដៅចម្បងបំផុតខ្លះៗរបស់គណៈកម្មការស្វែងរកការពិតអាចមានដូចជា ការទទួលស្គាល់បទឧក្រិដ្ឋកម្ម ការផ្តល់ឱកាសឲ្យជនរងគ្រោះនិយាយពីរឿងរ៉ាវរបស់ខ្លួននិងការផ្តល់ជារឿងរ៉ាវប្រវត្តិសាស្ត្រទាក់ទិននឹងកត្តាផ្សេងៗដែលបណ្តាលឲ្យមានអំពើសម្លាប់សាហាវឃោរឃៅទ្រង់ទ្រាយធំ ។ គណៈកម្មការស្វែងរកការពិតមានគោលដៅធ្វើយ៉ាងណាឲ្យយុវជនជំនាន់ក្រោយបានយល់ដឹងពីអ្វី ដែលបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនដោយភ្ជាប់ជាមួយនឹងគោលដៅចម្បងក្នុងការការពារមិនឲ្យអំពើសម្លាប់សាហាវឃោរ-ឃៅកើតឡើងម្តងទៀតឡើយ ។

ស្រដៀងគ្នានឹងតុលាការអន្តរជាតិ គណៈកម្មការស្វែងរកការពិតមានចំណុចខ្លាំង និងចំណុចខ្សោយផ្សេងៗក្នុងការដោះស្រាយអំពើហឹង្សាលើសិទ្ធិមនុស្ស ។ ជាទូទៅ មានក្តីបារម្ភពីរយ៉ាងដែលលើកឡើងដោយក្រុមអ្នកប្រាជ្ញគឺថា គណៈកម្មការស្វែងរកការពិតអាចនឹងបរាជ័យក្នុងការលាតត្រដាងពីការពិត បើទោះបីជាគណៈកម្មការនេះត្រូវបានចាត់ទុកថា បានធ្វើការឆ្លើយតបទៅតាមតម្រូវការរបស់ប្រទេសនីមួយៗក៏ដោយ ។ ដូច្នេះ ដំណើរការស៊ើបអង្កេតដ៏ម៉ត់ចត់លើអំពើហឹង្សាពីអតីតកាលអាចនឹងមិនមានលក្ខណៈសមស្របឬអាចប៉ះពាល់វប្បធម៌ចំពោះការពិតរបស់សង្គមដែលបានរងគ្រោះដោយអំពើហឹង្សាទ្រង់ទ្រាយធំ ។ ជាឧទាហរណ៍ គណៈកម្មការស្វែងរកការពិតបានទទួលបរាជ័យក្នុងការដោះស្រាយបញ្ហាអំពើសម្លាប់យ៉ាងសាហាវឃោរឃៅក្នុងទ្រង់ទ្រាយធំ ដែលជាប់ពាក់ព័ន្ធនឹងសហគមន៍អន្តរជាតិ ហើយមិនបានបំពេញទៅតាមតម្រូវការវប្បធម៌ ឬបានមើលរំលងប្រភេទជម្លោះ ដែលត្រូវបានដោះស្រាយកាលពីមុន ។

បើទោះបីជាត្រូវបានចាត់ទុកថាជាគណៈកម្មាគំរូដែលទទួលបានជោគជ័យខ្ពស់ក៏ដោយ ក៏គណៈ-កម្មការផ្សះផ្សារ និងស្វែងរកការពិតរបស់អាហ្វ្រិកខាងត្បូង នៅតែមានចំណុចខ្វះខាតដែលត្រូវរិះគន់ដដែល ។ អ្នកចូលរួមដែលជាជនរងគ្រោះខ្វះគិតថាខ្លួនគេមិនអាចនិយាយពី "ការពិត" ឬទទួលយកសំណងខូចខាតដែលអ្នកទាំងនេះបានទន្ទឹងរង់ចាំជាយូរមកហើយនោះទេ ។ ចំណែកគណៈកម្មការផ្សះផ្សានិង ស្វែងរកការពិតនៅ សៀរ៉ា ឡេអូន វិញក៏បានលើកឡើងពីក្តីព្រួយបារម្ភពីគណៈកម្មការស្វែងរកការពិតក្រោយកំឡុងពេលអំពើសម្លាប់សាហាវឃោរឃៅដែរ ។ ឧទាហរណ៍ ប្រជាជន សៀរ៉ា ឡេអូន មានមធ្យោបាយពិសេសរបស់ខ្លួនក្នុងការដោះស្រាយជម្លោះដោយធ្វើការ "ទទួលស្គាល់យោធាតស៊ូចងសម្ព័ន្ធមិត្តភាព និងស្តាបនាសហគមន៍ដែលប្រកបដោយសីលធម៌" ហើយអនុវត្តយន្តការបំភ្លេចចោលសង្គមអន្តរកាលដែលប្រើប្រាស់ឡើងដើម្បី "រំងាប់អារម្មណ៍" ជនរងគ្រោះ និងកសាងសហគមន៍របស់ខ្លួនសារជាថ្មីម្តងទៀត ។ ផ្ទុយទៅវិញ គណៈកម្មការផ្សះផ្សារ និងស្វែងរកការពិតនៅ សៀរ៉ា ឡេអូន បានរំខានដល់ដំណើរដោះស្រាយជម្លោះដែលអនុវត្តដោយប្រជាជនសៀរ៉ា ឡេអូន ដូចដែលបានលើកឡើងខាងលើ ។

## តម្រូវការរបស់ប្រទេសកម្ពុជា

គណៈកម្មការស្វែងរកការពិតនៅកម្ពុជាអាចនឹងជួយបំពេញបន្ថែមលើកិច្ចការរបស់តុលាការដែលមានរយៈពេលយូរដោយធ្វើឲ្យមានការចូលរួមច្រើន និងការទទួលស្គាល់ពីជនរងគ្រោះ ប្រសិន

បើគណៈកម្មការនេះត្រូវបានដំណើរការឡើង ដោយមានការយកចិត្តទុកដាក់យ៉ាងចម្បងលើការបំពេញទៅតាមល័ក្ខខ័ណ្ឌរបស់ប្រទេសកម្ពុជា ។ ការស្រាវជ្រាវឆ្នាំ២០០៩របស់សកលវិទ្យាល័យកាលីហ្វ័រញ៉ា រដ្ឋ ប៊ឺក្លេយ ស្តីពីតម្រូវការរបស់ប្រជាជនកម្ពុជាបានរកឃើញថា៨៥,៥ភាគរយ នៃអ្នកឆ្លើយតបបានយល់ស្របនឹងប្រយោគដែលថា«វាពិតជាមានសារសំខាន់ក្នុងការស្វែងរកការពិតពីអ្វីដែលបានកើតឡើងក្នុងអំឡុងរបបខ្មែរក្រហម» ។ ដូច្នេះ គណៈកម្មការស្វែងរកការពិតរបស់ប្រទេសកម្ពុជាគួរតែផ្តោតទៅលើការចងក្រងបទពិសោធន៍ប្រជាជនកម្ពុជាទុកជាឯកសារ និងវិភាគលើបទពិសោធន៍ទាំងនោះទាំងក្នុងកំឡុង និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ បង្កើតជាសាច់រឿងប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងអំពើហឹង្សាដោយរួមបញ្ចូលទាំងគោលបំណង និងការកកើតឡើងនៃរបបនេះ ហើយធ្វើការអប់រំជនរងគ្រោះ និងយុវជនជំនាន់ក្រោយពីប្រវត្តិសាស្ត្រកម្ពុជានេះ ។

មតិឆ្លើយតបទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានគោលដៅជួយដល់វិធានផ្លូវច្បាប់ការទាមទារយុត្តិធម៌ និងការផ្សះផ្សារត្រូវតែចាប់ផ្តើមឡើងដោយត្រូវសួរថា តើប្រជាជនដែលបានរស់នៅជំនាន់នោះចង់បានអ្វី ។ ការស្រាវជ្រាវរបស់សកលវិទ្យាល័យកាលីហ្វ័រញ៉ា រដ្ឋប៊ឺក្លេយ គូសបញ្ជាក់ឲ្យឃើញពីខ្លឹមសារសំខាន់ពីរដែលគួរតែធ្វើការដោះស្រាយ នៅក្នុងការបង្កើតជាគណៈកម្មាការស្វែងរកការពិតដើម្បីឲ្យគណៈកម្មាការនេះធ្វើការឆ្លុះបង្ហាញពីតម្រូវការរបស់សង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ ។

ទីមួយ ការស្រាវជ្រាវបង្ហាញឲ្យឃើញថាប្រជាជនកម្ពុជាពិតជាចង់ស្វែងរកការពិតពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ទីពីរ ឥរិយាបថរបស់ប្រជាជនកម្ពុជាមានចំពោះការរស់នៅជាមួយនឹងអតីតខ្មែរក្រហមបានគូសបញ្ជាក់ពីភាពស្មុំគ្រស្មាញនៃការផ្សះផ្សារ និងការដាក់ទោស ដែលមានក្នុងវប្បធម៌របស់ប្រទេសកម្ពុជា ។ គណៈកម្មការស្វែងរកការពិតភាគច្រើន ពឹងផ្អែកយ៉ាងខ្លាំងទៅលើការសហការពីជនដៃដល់ ដូច្នេះហើយបានជាការយល់ដឹងពីឥរិយាបថរបស់ប្រជាជនកម្ពុជាដែលមានចំពោះកម្មាភិបាលខ្មែរក្រហមជាន់ទាបមានសារសំខាន់ ។ សរុបមក ការស្រាវជ្រាវនេះបានបង្ហាញថាប្រជាជនកម្ពុជាចង់ឃើញជនដែលទទួលខុសត្រូវចំពោះរបបខ្មែរក្រហមត្រូវបានកាត់ទោស ហើយអ្នកទាំងអស់នេះជឿថា យុត្តិធម៌គឺជាដំណើរការមួយស្តីពីការលាតត្រដាងការពិត ។

ការស្ទាបស្ទង់មតិរបស់សកលវិទ្យាល័យកាលីហ្វ័រញ៉ា រដ្ឋប៊ឺក្លេយ គូសបញ្ជាក់ថាប្រជាជនកម្ពុជាភាគច្រើនចង់ដឹងពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ៧០ភាគរយនៃចំណោមអ្នកបានរស់នៅក្រោមរបបខ្មែរក្រហមបានអះអាងថា អ្នកទាំងនេះចង់ដឹងបន្ថែមទៀតពីអ្វីដែលបានកើតឡើងនៅ

ក្នុងរបបខ្មែរក្រហម ហើយ៨០ភាគរយនៃចំណោមអ្នកដែលមិនបានរស់នៅក្រោមរបបខ្មែរក្រហមក៏ចង់ដឹងពីរបបនេះដែរ ។ បើទោះបីជាប្រជាជនកម្ពុជាទាំងអ្នកបានរស់នៅឬមិនបានរស់នៅក្រោមរបបខ្មែរក្រហមចង់ស្វែងរកការពិតពីអ្វី ដែលបានកើតឡើងនៅក្នុងរបបនេះក៏ដោយ ក៏មានមនុស្សតិចជាង៥០ភាគរយមានឆន្ទៈចូលរួមនៅក្នុងការពិភាក្សាជាសាធារណៈ និងការនិយាយរៀបរាប់ពីបទពិសោធន៍របស់ខ្លួន ។

ទស្សនៈដែលឆ្លុះបង្ហាញពីការទទួលខុសត្រូវ ដោយប្រជាជនកម្ពុជានាពេលបច្ចុប្បន្ននេះបានគូសបញ្ជាក់ឲ្យឃើញពីការគាំទ្រយ៉ាងខ្លាំងក្លាចំពោះការកាត់ទោសជន ដែលទទួលខុសត្រូវចំពោះរបបខ្មែរក្រហម ។ ទោះបីជា៩៨ភាគរយនៃអ្នកដែលត្រូវបានស្ទាបស្ទង់មតិដោយការស្រាវជ្រាវរបស់សកល-វិទ្យាល័យ កាលីហ្វ័រញ៉ា វដ្ឋប៊ឺក្លេយ បានបញ្ជាក់ថាពួកគេជាពុទ្ធសាសនិកក៏ដោយ ក៏ការស្ទាបស្ទង់មតិនេះ មិនបានផ្តោតទៅលើការដាក់ទោសដែលផ្អែកលើមូលដ្ឋានវប្បធម៌នោះទេ ។ ដូច្នេះការស្រាវជ្រាវបន្ថែមចាំបាច់ត្រូវតែកំណត់ឲ្យបានច្បាស់លាស់ពីទម្រង់បែបបទនៃការដាក់ទោសនេះ ។ លើសពីនេះ បើទោះបីជា ជនជាតិភាគតិចអ៊ីស្លាមមានចំនួនតិចក៏ដោយ ក៏ទស្សនៈសាសនារបស់គេគួរតែត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការរបស់គណៈកម្មាការស្វែងរកការពិតនេះ ជាពិសេសគឺនៅក្នុងតំបន់ដែលមានប្រជាជនចាមរស់នៅច្រើន ។

បើនិយាយពីការទទួលខុសត្រូវវិញ អ្នកប្រាជ្ញខាងពុទ្ធសាសនាហីនយាន អាន ហារីស បានអះអាងថា ពុទ្ធសាសនិកកម្ពុជាបានយល់ស្របតាមខ្លឹមសារបីរបស់ព្រះពុទ្ធ ។ ខ្លឹមសារទាំងនេះគឺជាការគាំទ្រលើវិធានការអន្តរជាតិដែលនៅមានកម្រិតចំពោះតុលាការកាត់ទោស ដែលជាគោលដៅដើម្បីធានាថាការទទួលខុសត្រូវគោរពទៅតាមឥរិយាបថរបស់ពុទ្ធសាសនាហីនយាន និងជាការផ្តោតទៅលើការផ្សះផ្សារ "ដែលត្រូវបានយល់ថាជាការផ្សះផ្សាររបស់ពិភពលោកស្របទៅតាមផ្លូវធម៌" ។

ព្រះសង្ឃរបស់សាសនាព្រះពុទ្ធកម្ពុជា បានផ្តល់សេចក្តីណែនាំបន្ថែមលើអត្ថន័យនៃការផ្សះផ្សាតាមល័ក្ខខ័ណ្ឌវប្បធម៌ ។ ឧទាហរណ៍ លោកបណ្ឌិត ឡាវ ម៉ុងហាយ នាយកប្រតិបត្តិនៃវិទ្យាស្ថានលទ្ធីប្រជាធិបតេយ្យខ្មែរបានគាំទ្រការផ្សះផ្សាជាតិ ពីព្រោះវាមានទស្សនៈដូចគ្នានឹងទស្សនៈវិជ្ជារបស់ព្រះពុទ្ធដែរ ។ ការយកចិត្តទុកដាក់លើការរំសាយកំហឹងតាមផ្លូវព្រះពុទ្ធសាសនា គឺធ្វើឡើងដើម្បីលាងជម្រះចិត្តគំនិតគុំគួននោះតាមរយៈការធ្វើឲ្យសតិអារម្មណ៍ស្ងប់ស្ងាត់ និងដើម្បីការពារចំនងមិត្តភាពរវាងមនុស្សនិងមនុស្សទាំងអស់ ។

ក្រុមអ្នកប្រាជ្ញបានអះអាងថាការសុំខមាទោសជាថ្នាក់ជាតិ ដែលជាសកម្មភាពបង្ហាញការពិតជាផ្លូវការដែលត្រូវបានមើលឃើញដោយមេដឹកនាំសាសនា ហើយដែលមានព្រះមហាក្សត្រធ្វើជាគណៈ

អធិបតីយនោះ«អាចក្លាយជាការផ្តោតលើដំណើរការផ្សះផ្សារជាតិជានិមិត្តរូបបាន»។ ការប្រារព្ធពិធីរួមដូចជា ពិធីបុណ្យភ្ជុំបិណ្ឌអាចរៀបចំឡើង ដើម្បីបួងសួងដល់ដួងព្រលឹងអ្នកដែលបានស្លាប់បាត់បង់ជីវិតនៅក្រោមរបបខ្មែរក្រហមដើម្បីចាប់ផ្តើមការកាន់ទុក្ខ ការព្យាបាលរបួស និងដំណើរការផ្សះផ្សារ។ ការបំពេញទៅតាមតម្រូវការរបស់បុគ្គលនិងតម្រូវការរួម សម្រាប់ការកាន់ទុក្ខនេះមិនមែនជាកិច្ចការងាយស្រួលនោះទេ។ យ៉ាងណាមិញ វប្បធម៌កម្ពុជាក៏បានផ្តល់ជាសេចក្តីណែនាំមួយចំនួនដែរ។ ដូចគ្នានឹងពិធីបុណ្យភ្ជុំបិណ្ឌ គណៈកម្មការស្វែងរកការពិតគួរតែផ្តល់ឱកាសឲ្យបុគ្គលម្នាក់ៗធ្វើការចងចាំអ្នកដែលបានស្លាប់ទៅហើយនោះដោយបង្ហាញឲ្យឃើញពីសារសំខាន់ និងការយល់ដឹងពីវប្បធម៌។ ចុងក្រោយបង្អស់ គណៈកម្មាការស្វែងរកការពិតនឹងពឹងផ្អែកលើការចូលរួមរបស់បុគ្គលនីមួយៗ ការធ្វើដូច្នេះនឹងបង្កើតបរិកាសមួយដែលគ្មានការបែងចែករវាងជនដៃដល់ជនរងគ្រោះនិងអ្នកកាន់ទុក្ខដែលអាចនឹងជួយលើកតម្កើងការចងចាំ ការកាន់ទុក្ខ និងការផ្សះផ្សារបានយ៉ាងល្អជាមិនខាន។

មនុស្សមួយភាគធំដែលកំពុងរស់នៅជាមួយនឹងអតីតខ្មែរក្រហម បានរំឭកពីអារម្មណ៍ខឹងសម្បាររបស់ខ្លួន ហើយជាច្រើននាក់ទៀតមានបំណងចង់សងសឹក។ នេះគឺជាបញ្ហាវឹកវរ ពីព្រោះថាមនុស្សដែល ធ្លាប់ឆ្លងកាត់ការភ័យខ្លាច បញ្ហាជំងឺផ្លូវចិត្តអស់រយៈពេលយ៉ាងយូរ ហើយរងអំពើហឹង្សាដោយផ្ទាល់អាចនៅតែចងចាំសត្រូវរបស់ខ្លួន ហើយងាយនឹងរងគ្រោះ និងទទួលឥទ្ធិពលពីការបោកបញ្ឆោតផ្សេងៗ។ បញ្ហាមួយទៀតគឺថាកម្មាភិបាលខ្មែរក្រហមថ្នាក់កណ្តាល និងថ្នាក់ក្រោមកំពុងតែរស់នៅជាមួយនឹងជនរងគ្រោះយ៉ាងជិតស្និទ្ធ។តាមការស្រាវជ្រាវរបស់សកលវិទ្យាល័យ កាលីហ្វ័រញ៉ា រដ្ឋប៊ឺក្លេយបានធ្វើការកត់សម្គាល់ថាអ្នកចូលរួមនៅក្នុងការស្រាវជ្រាវនេះ «អាចលើកលែងទោសឲ្យជនបំរើខ្មែរក្រហមបាន ប៉ុន្តែអ្នកទាំងនេះនៅតែមានអារម្មណ៍ខឹងសម្បានឹងមេដឹកនាំខ្មែរក្រហម ឬអំពើហឹង្សាដែលកើតមានជាទូទៅនៅក្នុងរបបនេះ»។ បើពិចារណាពីឥរិយាបថរបស់ប្រទេសកម្ពុជាវិញ ការបង្កើតឲ្យមានជាយន្តការដោះស្រាយកំហឹងដ៏សមរម្យមួយពិតជាមានសារសំខាន់។ ការផ្សះផ្សារគឺជាការខិតខំប្រឹងប្រែងដែលចេញពីបុគ្គលផ្ទាល់ ប៉ុន្តែប្រហែលជាប្រព័ន្ធដោះស្រាយជម្លោះដោយផ្អែកលើគោលការរបស់ប្រទេសកម្ពុជា អាចផ្តល់ឱកាសឲ្យប្រជាជនកម្ពុជានិយាយពីរឿងរ៉ាវរបស់ខ្លួនទាំងក្នុងនាមជាជនរងគ្រោះ និងជនដៃដល់ ហើយអាចដោះស្រាយបញ្ហាពិរុទ្ធភាពនេះបាន។

បើទោះបីជាព័ត៌មានជាច្រើនស្តីពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមត្រូវបានប្រមូលផ្តុំអស់រយៈពេលជាច្រើនឆ្នាំដោយអង្គការផ្សេងៗគ្នាក៏ដោយ ក៏ព័ត៌មានស្តីពីឧក្រិដ្ឋកម្មនេះមិនទាន់ត្រូវបានចងក្រង និងចែកចាយជូនដល់ប្រជាជនកម្ពុជាមួយភាគធំនៅឡើយទេ។ ឧទាហរណ៍ លិខិតលើកលែងញត្តិរណៈស្សេបាន

ទាញយកសក្ខីកម្មពីមនុស្សរាប់ពាន់នាក់ ប៉ុន្តែព័ត៌មានទាំងនោះមិនត្រូវបានផ្សាយជាសាធារណៈទេ ។ គណៈកម្មការស្វែងរកការពិតអាចវិភាគនិងផ្សព្វផ្សាយព័ត៌មានទាំងនេះដោយធ្វើការទាក់ទាញឲ្យប្រជាជនកម្ពុជាចូលរួមនៅក្នុងដំណើរការនេះបាន ។

មកដល់ពេលនេះ គណៈកម្មការស្វែងរកការពិតអាចពឹងផ្អែកលើបទពិសោធន៍របស់រដ្ឋាភិបាលប្រទេសស៊ុយអែតបាន ។ ដោយព្រួយបារម្ភខ្លាចថា យុវជនស៊ុយអែតមានការយល់ដឹងតិចតួចពីការសម្លាប់រង្គាលដោយមានការជឿងឆ្ងល់នឹងការកកើតឡើងនៃអំពើនេះ និងបារម្ភពីការកើនឡើងនៃការឃោសនាតាមសាលារៀនរបស់ក្រុមមូលធននិយម រដ្ឋសភាប្រទេសស៊ុយអែតបានបង្កើតគម្រោងប្រវត្តិសាស្ត្ររស់ ។ គម្រោងនេះ មានគោលបំណងនិយាយពីរឿងរ៉ាវនៃការសម្លាប់រង្គាលតាមវិធី-សាស្ត្រផ្សេងៗរួម មានការប្រមូលផ្តុំធនធានព័ត៌មានសម្រាប់សាលារៀន ខ្សែភាពយន្ត សិក្ខាសាលានិងការប្រគុំតន្ត្រីជាដើម ។ គម្រោងនេះចាប់ផ្តើមឡើងនៅក្នុងការជជែកពិភាក្សាអន្តរជាតិនៅ ស្តុកខមដែលមានការប្រជុំសិក្ខាសាលាអន្តរជាតិចំនួនបួន ដែលធ្វើឡើងក្នុងគោលបំណងបង្កើតវេទិកា«ប្រជុំមួយដើម្បីផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង គំនិត និងទស្សនៈរវាងអ្នកប្រាជ្ញ អ្នកធ្វើសេចក្តីសម្រេច និងអ្នកជាប់ពាក់ព័ន្ធ» ។ មុនពេលសិក្ខាសាលាលើកទីមួយចាប់ផ្តើម រដ្ឋាភិបាលស៊ុយអែតបានបោះពុម្ពសៀវភៅមួយក្បាលដែលមានចំណងជើងថា *Tell Ye Your Children* ដែលធ្វើការនិយាយពីការសម្លាប់រង្គាលនៅសហគមន៍អឺរ៉ុប ។ សៀវភៅថតចម្លងប្រមាណ១,២លានក្បាលដែលបកប្រែជាភាសាហ្វាំងឡង់ អារ៉ាប់ ទួគី សឺបូក្រូស្យៀន អង់គ្លេស អេស្ប៉ាញ និងពឺសង់ ត្រូវបានចែកជូនកូនសិស្សសាលារបស់គ្រួសារជនជាតិស៊ុយអែតគ្រប់ៗគ្នា ។ ក្រោយពេលដែលសិក្ខាសាលានេះបានបញ្ចប់ទៅ រដ្ឋាភិបាលស៊ុយអែតបានបោះពុម្ពសៀវភៅមួយក្បាលទៀតដែលមានចំណងជើងថា *Beyond the "Never agains"* ដែលសៀវភៅនេះធ្វើការគូសបង្ហាញពីការស្រាវជ្រាវរបស់សិក្ខាសាលា និងរួមជាមួយនឹងបទសម្ភាសន៍ជាមួយនឹងអ្នកចូលរួមមួយចំនួនទៀត ។ ពិតណាស់ គម្រោងស្តីពីការលើកកម្ពស់ការយល់ដឹងស្រដៀងគ្នានៅប្រទេសកម្ពុជា អាចនឹងចាំបាច់ត្រូវតែបំពេញទៅតាមបរិបទវប្បធម៌របស់កម្ពុជា ប៉ុន្តែវិធីសាស្ត្រសម្រេចនូវជោគជ័យច្រើនបែបនេះអាចនឹងផ្តល់នូវគំរូដ៏ល្អសម្រាប់គណៈកម្មការស្វែងរកការពិតរបស់កម្ពុជាបាន ។

## ការស្នើសុំ

ការស្នើសុំបច្ចុប្បន្ននេះគឺដើម្បីបង្កើតគម្រោងមួយដែលនឹងចាប់ផ្តើមដំណើរការដោយការប្រមូលយកសក្ខីភាពពីប្រជាជនកម្ពុជាស្តីពីបទពិសោធន៍របស់គេកាលពីរបបខ្មែរក្រហម តាមរយៈវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀននៅតាមសហគមន៍ និងការសហការពីសំណាក់ព្រះសង្ឃ ។ កិច្ចប្រឹងប្រែងនេះនឹងធ្វើការវិវត្តន៍ក្នុងរយៈពេលពីបីឆ្នាំខាងមុខទៅប្រាំឆ្នាំទៀត ដើម្បីបញ្ចូលសក្ខីភាពសំខាន់ៗជាច្រើន ជាថ្នាក់ជាតិនិងដើម្បីឆ្លើយតបនឹងសំណួរពីការកកើតឡើងនៃរបបខ្មែរក្រហមនិងឥទ្ធិពលរបស់របបនេះ មកលើប្រទេសកម្ពុជា ។

គ្រូបង្រៀនអាចនឹងត្រូវចាត់តាំងឲ្យធ្វើបទសម្ភាសន៍ ចងក្រងព័ត៌មាន ហើយដឹកនាំការឃោសនាអប់រំ ។ គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលកំពុងដំណើរការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាព្យាយាមផ្លាស់ប្តូរនិន្នាការ ដែលចៀសវាងមិនបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសាលារៀន ។ បច្ចុប្បន្ននេះសិស្សសាលាគ្រប់វ័យទាំងអស់មិនបានទទួលការអប់រំជាផ្លូវការស្តីពីរបបនេះទេដោយសារតែការផ្តោតទៅលើសារសំខាន់នៃប្រវត្តិសាស្ត្រសម័យទំនើបនិងព្រឹត្តិការណ៍ដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ។ ក្រោយពីការរៀបរៀងជាសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងសៀវភៅណែនាំគ្រូបង្រៀន មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនទាំងបីកម្រិតហើយដាក់បញ្ចូលសៀវភៅទាំងនេះ ចូលទៅក្នុងកម្មវិធីសិក្សានេះដើម្បីបង្រៀននៅតាមវិទ្យាល័យទូទាំងប្រទេសកម្ពុជា ។ គ្រូបង្រៀនទាំងអស់នេះគឺជាអ្នកដើរតួយ៉ាងល្អក្នុងការពង្រីកសកម្មភាពអប់រំ ដែលចាប់ផ្តើមចេញពីការបង្រៀនសិស្សតាមសាលារៀនឈានទៅដល់ការអប់រំតាមសហគមន៍ធំៗដើម្បីចងក្រងប្រវត្តិសាស្ត្រនេះ ។ការពង្រីកសកម្មភាពអប់រំរបស់គ្រូបង្រៀនទាំងអស់នេះអាចធ្វើទៅបាន ដោយសារតែអ្នកទាំងនេះទទួលបានសេចក្តីគោរពរាប់អានពីអ្នកភូមិក្នុងសហគមន៍របស់គេ និងដោយសារតែចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

សៀវភៅប្រវត្តិសាស្ត្រនេះគឺជាផ្នែកមួយនៃកម្មវិធីអប់រំ ដែលផ្តល់ជូនអ្នកដែលកើតក្រោយរបបខ្មែរក្រហម ។ ថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានកំពុងដាក់តាំងពាក្យស្លោកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នៅតាមសាលារៀនក្នុងប្រទេសកម្ពុជាដើម្បីលើកកម្ពស់ការយល់ដឹងរបស់សិស្សនិងគ្រូបង្រៀនពីអំពើប្រល័យពូជសាសន៍ និងដើម្បីរារាំងអំពើប្រល័យពូជសាសន៍ ។ គណៈកម្មការស្វែងរកការពិតរបស់ប្រទេសកម្ពុជាអាចនឹងបង្កើតជាកិច្ចប្រឹងប្រែងទាំងនេះបាន ។

នៅក្នុងប្រទេសដែលពោរពេញទៅដោយអ្នកកាន់សាសនាព្រះពុទ្ធ ព្រះសង្ឃគឺជាប្រភពផ្តល់ដំបូន្មាន និងបញ្ញាដែលទទួលបានការគោរពដ៏ខ្ពង់ខ្ពស់ ។ បើទោះបីជាបារាំងបានបង្កើតប្រព័ន្ធច្បាប់លោក

ខានលិចក៏ដោយ ក៏គំរូដោះស្រាយជម្លោះក្នុងស្រុករបស់ប្រទេសកម្ពុជានៅតែបន្តថិតថេររហូតមក ។ ដូចគ្នានឹងប្រព័ន្ធដោះស្រាយជម្លោះផ្សេងទៀតទំនាក់ទំនងរវាងភាគីទាំងអស់ពិតជាមានសារសំខាន់ ។ បន្ថែមលើនេះ ជាធម្មតាប្រជាជនកម្ពុជា « បានចាត់ទុកជម្លោះមួយជាកត្តាដែលធ្វើឲ្យប៉ះពាល់ដល់ចំណង មិត្តភាពយូរយាររបស់គេ » ។ ជាមួយគ្នានេះ សមាសធាតុផ្នែកសាសនាបានដើរតួជាផ្នែកដ៏សំខាន់មួយ នៅក្នុងគំរូដោះស្រាយជម្លោះ ។ ព្រះសង្ឃនៅតែបន្តទទួលបានការគោរព និងកោតសរសើរ ហើយ អាចនឹងត្រូវបានចាត់ទុកជាភាគីទីបី ដែលចូលរួមនៅក្នុងទម្រង់ដោះស្រាយជម្លោះតាមបែបប្រពៃណី ។ ដូច្នេះ ព្រះសង្ឃគឺជាបុគ្គលដែលស័ក្តិសមធ្វើជាអ្នកបង្កើតវិធីសាស្ត្រដោះស្រាយជម្លោះបន្ថែមលើវិធី សាស្ត្រដែលមាននៅតាមភូមិ ហើយធ្វើការពិភាក្សាពីការដាក់ទោសដែលមានលក្ខណៈស្របទៅតាមព្រះ ពុទ្ធសាសនាហីនយាន ។ ជាមួយគ្នានេះ មេដឹកនាំរបស់ជនជាតិភាគតិចចាមគួរតែចូលរួមនៅក្នុងការ រៀបចំគណៈកម្មការស្វែងរកការពិតរបស់កម្ពុជានេះដែរ ។

គម្រោងនេះនឹងចាប់ផ្តើមដំណើរការឡើងជាក្រុមការងារគ្រូបង្រៀន ដែលទទួលបានវគ្គបណ្តុះ បណ្តាលពីមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈគម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ គ្រូ បង្រៀនទាំងអស់នេះនឹងត្រូវបានជ្រើសរើសពីវិទ្យាល័យថ្នាក់ឃុំ ស្រុក និងជាតិ ដើម្បីធ្វើឲ្យការធ្វើជា តំណាងមានលក្ខណៈធំទូលាយ ហើយចុះធ្វើការងារគ្រប់តំបន់ទូទាំងប្រទេសកម្ពុជា ។ នៅក្នុងចំណោម គ្រូបង្រៀនចំនួន២០០នាក់ ដែលនឹងចូលរួមនៅក្នុងគម្រោងនេះនឹងមានការជ្រើសតាំងគណៈកម្មាធិការ ប្រតិបត្តិតូចមួយដើម្បីជួយរៀបចំ និងដឹកនាំក្រុមគ្រូបង្រៀនទាំងអស់ ។ គណៈកម្មាធិការប្រតិបត្តិនេះ មានសមាជិកចាប់ពីប្រាំទៅប្រាំពីរនាក់ ដែលត្រូវបានជ្រើសតាំងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើចំណាប់អារម្មណ៍ និងសកម្មភាពរបស់គ្រូបង្រៀនទាំងនោះនៅក្នុងកំឡុងវគ្គបណ្តុះបណ្តាល ការអប់រំក្រោយពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីធានាថាគ្រូបង្រៀនទាំងអស់នេះមានឆន្ទៈ មោះមុតក្នុងការចងក្រង និងបង្រៀនប្រវត្តិសាស្ត្រកម្ពុជា ។ សម្រាប់ក្រុមការងារគ្រូបង្រៀនក្រុមធំ វិញនឹងត្រូវទទួលបានការផ្តោតយកចិត្តទុកដាក់ខ្លាំង ដើម្បីធានាថាក្រុមការងារនេះដើរតួជាអ្នកតំណាងឲ្យ តំបន់ ភូមិសាស្ត្រ យេនឌ័រ ជាតិពន្ធុ សាសនា បទពិសោធន៍បង្រៀន និងប្រជាសាស្ត្រផ្សេងៗ ។ គណៈកម្មាធិការប្រតិបត្តិនៃក្រុមការងារនេះនឹងធ្វើការដោយស្ម័គ្រចិត្ត ហើយកិច្ចការរបស់គណៈកម្មា ធិការនេះគឺរក្សាទំនាក់ទំនងជាចំហរជាមួយគ្រូបង្រៀនទាំងអស់ ដោយរៀបចំជាគម្រោងកំណត់ពេល វេលាសម្រាប់ការចងក្រងព័ត៌មាន និងរៀបចំការប្រជុំប្រចាំឆ្នាំ ។

ដំណើរការចាប់ផ្តើមរបស់គម្រោងនេះ និងការប្រជុំប្រចាំឆ្នាំជាលើកដំបូងនឹងនាំយកមេដឹកនាំ សាសនាមកពីគ្រប់តំបន់និងគ្រូបង្រៀនចំនួន២០០នាក់ទៀតមកចូលរួមពិភាក្សា និងទទួលយកវគ្គបណ្តុះ

បណ្តាលសម្រាប់ជំនាញផ្សេងៗបន្ថែមទៀតនៅក្នុងកំឡុងពេលបំពេញការងារ ។ ជាឧទាហរណ៍ គ្រូបង្រៀននឹងទទួលបានវគ្គបណ្តុះបណ្តាលពីអ្នកជំនាញទាក់ទងនឹងបញ្ហាផ្លូវចិត្ត និងសង្គម វិធីសាស្រ្តធ្វើបទសម្ភាសន៍ និងវិធីសាស្រ្តជួយសម្រួលដល់ការពិភាក្សាជាក្រុម ។ ក្នុងរយៈពេលពេញមួយឆ្នាំ គ្រូបង្រៀនទាំងអស់នឹងធ្វើការជាមួយនឹងប្រជាជនក្នុងសហគមន៍របស់ខ្លួនដើម្បីកត់ត្រា និងចងក្រងសក្ខីភាពរបស់ប្រជាជនស្តីពីការកកើតឡើង ច្បាប់ ការដួលរំលំរបស់របបខ្មែរក្រហម និងលទ្ធផលក្រោយរបបនេះរលត់ផុតទៅ ហើយស្របពេលជាមួយគ្នានោះដែរ ព្រះសង្ឃនឹងបង្កើតវិធីសាស្រ្តសម្រាប់ការផ្សះផ្សារ ។

គោលដៅដ៏មានឥទ្ធិពលនេះនឹងត្រូវធ្វើឡើង ដើម្បីបង្កើតជារឿងរ៉ាវដ៏ធំមួយស្តីពីរយៈពេលដ៏សំខាន់នៃប្រវត្តិសាស្រ្តកម្ពុជា ។ ការស្វែងរករឿងរ៉ាវនេះនឹងក្លាយជាជំហានដំបូងក្នុងការបង្កើតបរិយា-កាស ដែលឆ្ពោះទៅរកការផ្សះផ្សារសង្គម ។ ដំណើរការនេះអាចចាប់ផ្តើមដោយធ្វើយ៉ាងណាឲ្យប្រជាជននៅតាមសហគមន៍ចូលរួមរៀបរាប់ពីរឿងរ៉ាវរបស់គេ ដែលផ្តោតទៅលើកត្តាការកកើតឡើងឥទ្ធិពលអាក្រក់របស់របបពលប៉ុលដែលមាននាពេលបច្ចុប្បន្ន និងការប្រាស្រ័យទាក់ទងរវាងជនដៃដល់និងជនរងគ្រោះ ។ ដំណើរការនេះគួរតែធ្វើការយកចិត្តទុកដាក់លើរឿងរ៉ាវនៅតាមថ្នាក់ភូមិ និង ទម្រង់ដើមនៃយុត្តិធម៌តាមរយៈការផ្សះផ្សារតាមផ្លូវច្បាប់ និងការអប់រំដែលជួយលើកកម្ពស់សាមគ្គីភាព ។

សក្ខីកម្មរបស់អតីត«ខ្មែរក្រហម»ពិតជាមានសារសំខាន់ពីព្រោះបុគ្គលទាំងអស់នេះមានការយល់ដឹងច្រើនពីទស្សនៈវិជ្ជារបស់ខ្មែរក្រហម រចនាសម្ព័ន្ធ និងតួនាទីរបស់របបនេះ និងខ្សែបណ្តាញបញ្ជា ។ រឿងរ៉ាវដែលទទួលបានពីកម្មាភិបាលថ្នាក់ទាប និងជនរងគ្រោះស្តីពីការចូលរួមរបស់ប្រជាជននឹងជួយបង្កើតជាការយល់ដឹងមួយស្តីពីកត្តាដែលនាំឲ្យមានឧក្រិដ្ឋកម្មកើតឡើង ។ ជាមួយគ្នានេះ អតីតជនដៃដល់ក៏អាចសហការជាមួយនឹងគ្រូបង្រៀននិងព្រះសង្ឃនៅក្នុងសហគមន៍របស់ខ្លួន ដើម្បីចែករំលែករឿងរ៉ាវ និងបទពិសោធន៍របស់ខ្លួនជាមួយនឹងគម្រោងគណៈកម្មាការស្វែងរកការពិតដើម្បីជម្រុញឲ្យមានការចូលរួមកាន់តែច្រើនពីសំណាក់អតីតកម្មាភិបាលខ្មែរក្រហមផ្សេងទៀត ។ ការទាក់ទាញឲ្យអតីតជនដៃដល់ធ្វើការសហការនៅក្នុងគម្រោងនេះអាចនឹងប្រឈមមុខជាមួយបញ្ហាដ៏ធំមួយទាក់ទិននឹងដំណើរការចូលរួមពិភាក្សានេះ ពីព្រោះថាការបែងចែកដាច់ដោយឡែកថានរណាជាជនរងគ្រោះ និងជនដៃដល់នៅតែមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ ។

ជារៀងរាល់ឆ្នាំ ការប្រជុំប្រចាំឆ្នាំនឹងប្រារព្ធឡើង ដោយមានការចូលរួមពីគ្រូបង្រៀនទាំងអស់ដើម្បីបូកសរុបព័ត៌មានដែលប្រមូលបានពេញមួយឆ្នាំ ។ សម្រាប់អ្នកចូលរួមដែលចង់ចែករំលែកបទពិសោធន៍របស់ខ្លួននោះ ទិន្នន័យដែលទទួលបានពីបទពិសោធន៍ទាំងអស់នេះអាចត្រូវបានរៀបចំបោះពុម្ព

ជាសាច់រឿងមួយដែលនឹងត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការប្រតិបត្តិគ្រូបង្រៀន អ្នកជំនាញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងអ្នកដឹកនាំផ្នែកប្រវត្តិសាស្ត្រកម្ពុជាផ្សេងទៀត ដើម្បីបង្កើតជាសាច់រឿងរួមធំមួយ ដែលទទួលបានព័ត៌មានពីប្រជាជនទូទាំងប្រទេសស្តីពីព្រឹត្តិការណ៍ទាំងអស់ដែលកើតមានកាលពីអតីតកាល ។ ដើម្បីធ្វើឲ្យគណៈកម្មការស្វែងរកការពិតដំណើរការទៅបាន ក្រុមអាជ្ញាធរឯករាជ្យមួយត្រូវតែទទួលបានអំណាចក្នុងការប្រើប្រាស់ទិន្នន័យសម្រាប់ការស្រាវជ្រាវ ដែលឆ្លើយតបនឹងសំណួរ ដែលទាក់ទងនឹងកត្តាជម្រុញឲ្យមានការកកើតឡើងនៃរបបនេះ និងបទពិសោធន៍ដែលកើតឡើងជាទូទៅ ។ ការបោះពុម្ពដែលជាលទ្ធផលនៃដំណើរការនេះនឹងត្រូវយកមកប្រើប្រាស់ ដើម្បីជួយផ្សំផ្សំបន្ថែមដល់ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមវិទ្យាល័យនិងមហាវិទ្យាល័យតាមរយៈគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយការបោះពុម្ពទាំងនេះនឹងត្រូវចែកជូនដល់សាធារណជនទូទៅដើម្បីបង្កើនការយល់ដឹងពីប្រវត្តិសាស្ត្រនេះ ។ ក្រោយមកទៀតប្រឹត្តិការណ៍ទាញយកព័ត៌មានបែបនេះអាចនឹងធ្វើឡើងនៅតាមថ្នាក់ស្រុក និងថ្នាក់ជាតិ ដើម្បីប្រមូលផ្តុំទិន្នន័យនិងផ្សព្វ-ផ្សាយ ការស្រាវជ្រាវឲ្យកាន់តែទូលំទូលាយ ។

បន្ថែមលើការចងក្រងសក្ខីភាពតាមរយៈបទសម្ភាសន៍និងការសរសេររឿងរ៉ាវរបស់ជនរងគ្រោះទាំងអស់នៅក្នុងរបបខ្មែរក្រហម និងអ្នកដែលកើតក្រោយរបបនេះ គ្រូបង្រៀននៅតាមភូមិ និងទីរួមស្រុកទាំងអស់អាចនឹងទទួលការណែនាំឲ្យរៀបចំជាវេទិកាពិភាក្សាក្នុងសហគមន៍ ។ ប្រជាជននៅក្នុងសហគមន៍ទាំងអស់នឹងមិនត្រូវបានបង្ខិតបង្ខំឲ្យចូលរួមនៅក្នុងវេទិកាពិភាក្សានេះទេ ។ ព្រឹត្តិការណ៍ពិភាក្សានេះ នឹងផ្តល់ជាឱកាសចែករំលែក និងសន្ទនាពីបញ្ហាកាលពីសម័យខ្មែរក្រហមដែលនឹងជួយសម្រួលដោយគ្រូបង្រៀនម្នាក់ ។ មេដឹកនាំខាងសាសនាក្នុងសហគមន៍ក៏គយរតែចូលរួមនៅក្នុងវេទិកាពិភាក្សានេះដែរដោយសារតែមេដឹកនាំទាំងនេះអាចទាញយកភាពជឿជាក់ពីអ្នកភូមិ និងដោយសារតែបទពិសោធន៍របស់មេ ដឹកនាំទាំងនេះក្នុងការដោះស្រាយបញ្ហាសីលធម៌ និងបញ្ហាផ្លូវចិត្ត ។ បន្ថែមលើការរៀបរាប់រឿងរ៉ាវជាសាធារណៈ ទម្រង់នៃការបង្ហាញឲ្យឃើញពីអារម្មណ៍របស់បុគ្គលតាមទំនៀមទម្លាប់ប្រពៃណីដូចជាតាមរយៈតន្ត្រីឬកំណាព្យអាចនឹងត្រូវបានប្រើប្រាស់ដោយចេញពីការផ្តួចផ្តើមឡើងពីសំណាក់អ្នកភូមិ ។ វេទិកាពិភាក្សាទាំងអស់នេះនឹងធ្វើឲ្យគម្រោងនេះមានលក្ខណៈខុសប្លែកពីការចងក្រងសក្ខីភាពខាងលើ ។

វេទិកាពិភាក្សាអាចនឹងប្រើប្រាស់ទម្រង់បែបបទស្រដៀងគ្នាដែលត្រូវបានប្រើប្រាស់នៅក្នុងព្រឹត្តិការណ៍ ដូចជាថ្ងៃចងកំហឹងជាដើម ។ ចាប់តាំងពីទសវត្សរ៍៩០មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានលើកកម្ពស់ការចងចាំពីរបបប៉ុលពតដោយជម្រុញឲ្យមន្ទីរពេទ្យ សាលារៀន និងរោងចក្រនានា ធ្វើបជា

ឬផ្ទាំងរូបភាពស្តីអំពីការប្រឆាំងនឹងរបបខ្មែរក្រហម ដើម្បីយកមកប្រើប្រាស់នៅក្នុងកិច្ចពិភាក្សាជាសាធារណៈនិងព្រឹត្តិការណ៍រំឭកផ្សេងៗ ។ ការជួបជុំពិភាក្សានៅក្នុងថ្ងៃចងកំហឹងដែលតែងតែប្រារព្ធធ្វើនៅតាមទីកន្លែងវប្បធម៌សំខាន់ៗ អ្នកចូលរួមត្រូវបានលើកទឹកចិត្តឲ្យចូលរួម និងចែករំលែករឿងរ៉ាវរបស់ខ្លួន ។ សកម្មភាពបស់បុគ្គលទាំងអស់នេះមានតុល្យភាព ជាមួយ«ការសរសេររៀបរៀងជាផ្លូវការមួយដែលសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការធ្វើឲ្យអារម្មណ៍ផ្លូវចិត្តស្ងប់ និងការផ្តោតយកចិត្តទុកដាក់ទៅលើការ ប្រឆាំងនឹងការបំភ្លេច ដែលកត្តាទាំងនេះពិតជាមានសារសំខាន់ក្នុងការកសាងជាតិឡើងវិញ» ។ ដូចគ្នាដែរវេទិកាពិភាក្សានៅតាមសហគមន៍ត្រូវតែធ្វើការពង្រឹងគោលដៅពីរខាងលើនេះ ហើយធ្វើយ៉ាងណា ផ្តល់នូវទីកន្លែងមួយដែលអ្នកចូលរួមមានអារម្មណ៍ងាយស្រួលក្នុងការបង្ហាញពីកំហឹង និងការឈឺចាប់របស់ខ្លួន ។

ស្របពេលដែលគ្រូបង្រៀននឹងក្លាយជាអ្នកដើរតួ និងអ្នករៀបចំដ៏សំខាន់នៅក្នុងការអនុវត្តស្វែងរកការពិតនេះ ទាំងរាជរដ្ឋាភិបាលកម្ពុជា និងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្តល់នូវធនធាន និងបទពិសោធន៍សំខាន់ជាច្រើនដល់ដំណើរការនេះ ។ រាជរដ្ឋាភិបាលអាចនឹងផ្តល់អំណាច និងភាពត្រឹមត្រូវតាមផ្លូវច្បាប់ក៏ដូចជាធ្វើឲ្យមានការយកចិត្តទុកដាក់ពីសារព័ត៌មានទៅលើដំណើរការនេះ ។ បន្ថែមលើនេះមន្ត្រីរដ្ឋាភិបាលដែលបានចូលរួមនៅក្នុងការរៀបចំព្រឹត្តិការណ៍ផ្សេងៗដូចជា ពិធីរំឭកថ្ងៃចងកំហឹងនៅថ្ងៃទី២០ ខែឧសភា និងថ្ងៃទី៧ ខែមករា ក៏អាចចែករំលែកនូវទេពកោសល្យ និងចំណេះដឹងផ្សេងៗរបស់ខ្លួនបានដែរ ។ រាជរដ្ឋាភិបាលក៏អាចផ្តល់ជាធនធានមិនមែនជាថវិកាដូចជាទីកន្លែងប្រជុំការផ្សព្វ-ផ្សាយព័ត៌មានជាផ្លូវការ និងការគាំទ្រជាសាធារណជាដើម ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្តល់នូវបទពិសោធន៍ស្តីពីការចងក្រងរឿងរ៉ាវរបស់ប្រជាជនក្នុងរយៈពេលមួយទសវត្សកន្លងទៅនេះហើយអាចនឹងផ្តល់ជាសេចក្តីណែនាំបច្ចេកទេសសម្រាប់ការបោះពុម្ព ។ ទាំងរាជរដ្ឋាភិបាលកម្ពុជា និងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងដើរតួយ៉ាងចម្បងនៅក្នុងការដំណើរការគណៈកម្មាការនេះប៉ុន្តែខណៈពេលដែលគណៈកម្មការនេះកំពុងបន្តដំណើរការគណៈកម្មាធិការប្រឹក្សាដែលដំណើររយៈពេលយូរអាចនឹងត្រូវបានជ្រើសតាំងឡើងដែលមានអ្នកតំណាងពីរាជរដ្ឋាភិបាលកម្ពុជាមជ្ឈមណ្ឌលកម្ពុជា និងអតីតសមាជិកគណៈម្មការដែលមកពីគណៈកម្មការស្វែងរកការពិតផ្សេងទៀត ។

ស្របពេលដែលគម្រោងនេះដំណើរការដល់ដំណាក់កាលបោះពុម្ពជាសៀវភៅហើយព្រឹត្តិការណ៍របស់គម្រោងនេះត្រូវបានរៀបចំឡើងលើសពីថ្នាក់សហគមន៍នីមួយៗនោះ សិស្សវិទ្យាល័យនិងនិស្សិតមហាវិទ្យាល័យក៏ដើរតួរនៅក្នុងដំណើរការនេះដែរ ។ ដោយដើរតួជាអ្នកពង្រីកការអប់រំពីប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀន សិស្សនិស្សិតទាំងអស់នេះអាចធ្វើការស្ម័គ្រចិត្ត ជួយប្រមូល

រៀបចំ  និងបោះពុម្ពឯកសារបន្ទាប់បន្សំផ្សេងៗ ។  ការធ្វើដូច្នេះមិនមែនត្រឹមតែធ្វើឲ្យមានការចូលរួមពីសំណាក់  យុវជនជំនាន់ក្រោយ  និងជួយសម្រេចគោលដៅរារាំងអំពើសាហាវឃោរឃៅតែប៉ុណ្ណោះទេ វាថែមទាំងជួយធ្វើឲ្យមានការចំណាយថវិកាតិចទៅលើការចងក្រងឯកសារថ្មីៗទៀត ។  សិស្សមហា-វិទ្យាល័យអាចជួយក្រុមការងារគ្រូបង្រៀននៅក្នុងការចងក្រងសក្ខីភាពរបស់អ្នកមានឋានៈខ្ពស់  និងចូលរួមនៅក្នុងព្រឹត្តិការណ៍ឬពិធីផ្សេងៗដើម្បីអបអរសាទរចំពោះដំណើរការឆ្ពោះទៅមុខរបស់គម្រោងគណៈកម្មការស្វែងរកការពិតនេះ ។

## ការវិភាគលើរចនាសម្ព័ន្ធ និងសេចក្តីណែនាំដល់គម្រោងនេះ

គម្រូដែលបានស្នើឡើងខាងលើនេះមានផលវិជ្ជមានច្រើន  ក្នុងការស្វែងយល់ពីអតីតកាលរបស់កម្ពុជា ។  ទីមួយដំណើរការខាងលើនេះ  មានលក្ខណៈក្រៅផ្លូវការហើយមានផលប៉ះពាល់តិចតួចណាស់លើជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា  និងនយោបាយជាតិ ។  ការចូលរួមរបស់មនុស្សគ្រប់លំដាប់ថ្នាក់គឺផ្តើមចេញពីការស្ម័គ្រចិត្ត ។  លើសពីនេះ  គណៈកម្មការស្វែងរកការពិតនេះគឺជួយបំពេញកិច្ចការបន្ថែមរបស់តុលាការកូនកាត់នេះ  និងដោយសារតែរចនាសម្ព័ន្ធដែលប្រើប្រាស់ថវិកាទាបរបស់ខ្លួនគណៈកម្មាការស្វែងរកការពិតនេះ  អាចបន្តកិច្ចការរបស់ខ្លួនបានរយៈពេលយ៉ាងយូរបំផុត ។  ខុសពីតុលាការដែលយល់ថាការស្វែងរកទោសកំហុស  និងភាពស្អាតស្អំរបស់ជនជាប់ចោទគឺជាគោលដៅចម្បងនោះ គណៈកម្មាការនេះបានធ្វើឲ្យមនុស្សជាច្រើននាក់អាចចូលរួម  និងធ្វើឲ្យបទពិសោធន៍របស់អ្នកទាំងនេះត្រូវបានទទួលស្គាល់ជាផ្លូវការ ។  ដូចការរៀបរាប់ខាងលើ  គោលការណ៍របស់ពុទ្ធសាសនិកធ្វើការគាំទ្រទស្សនៈដែលថាគម្រោងគណៈកម្មការស្វែងរកការពិតនឹងជួយបំពេញកិច្ចការបន្ថែមរបស់តុលាការ ។ គណៈកម្មការស្វែងរកការពិតមានលក្ខណៈដូចនិងយុត្តិធម៌តាមរយៈការផ្សះផ្សារតាមផ្លូវច្បាប់ដែរ  ប៉ុន្តែមិនដូចគ្នានឹងវិធានការផ្តន្ទាទោសដែលសម្រេចបានតាមរយៈការកាត់ទោសនោះទេ ។នៅក្នុងពុទ្ធសាសនាហីនយាន  ការទទួលស្គាល់ពីកំហុសនិងការកំណត់គោលដៅល្អសម្រាប់អនាគតគឺជាសមាសធាតុដ៏សំខាន់ក្នុងការចៀសវាងការប្រព្រឹត្តអំពើហឹង្សា ។  ដូច្នេះវេទិកាពិភាក្សានិងការធ្វើសក្ខីភាពគឺជាមាគ៌ាមួយដែលធ្វើឲ្យមានការទទួលស្គាល់  និងបង្កើតជាមូលដ្ឋានសម្រាប់ការផ្សះផ្សារ ។

អត្ថប្រយោជន៍ដ៏សំខាន់បំផុតមួយនៃគំរូរបស់គណៈកម្មាការស្វែងរកការពិតនេះគឺថា  វាចាប់ផ្តើមដំណើរការឡើងនៅតាមសហគមន៍ ។  លក្ខណៈប្រែប្រួលក្នុងតំបន់អាចត្រូវបានក្តោបក្តាប់បានតាមរយៈដំណើរការចេញពីថ្នាក់មូលដ្ឋានបែបនេះហើយការចូលរួមដ៏ពិតប្រាកដនឹងអាចកើតមានឡើងរវាងប្រជាជនជនកម្ពុជាពីថ្នាក់ទាបមិនមែនត្រឹមតែថ្នាក់ជាតិប៉ុណ្ណោះទេ ។  ការធ្វើដំណើរទៅសួរសុខទុក្ខ  និងការអប់រំ

នៅតាមភូមិនឹងត្រូវធ្វើឡើងក្នុងបរិយាបថប្រកបដោយការយល់ដឹងពីការប្រាស្រ័យទាក់ទងនៅក្នុងភូមិដែលទាក់ទាញអ្នកភូមិឲ្យចូលរួមនៅក្នុងការពិភាក្សាជាសាធារណៈ និងការសួរសុខទុក្ខតាមផ្ទះរបស់ខ្លួនទៅវិញទៅមក ។

ខណៈពេលដែលព្រឹត្តិការណ៍ទាំងនេះត្រូវបានរៀបចំឡើងនៅតាមថ្នាក់ខ្ពស់ ហើយទិន្នន័យត្រូវបានវិភាគ ដើម្បីស្រាវជ្រាវពីសាច់រឿងពីអតីតកាលមួយនោះ មេរៀនដកស្រង់ចេញពីអតីតកាល និងអនាគតទាំងអស់នេះនឹងក្លាយជាផ្នែកមួយនៃការយល់ដឹងរបស់ប្រទេសជាតិ ។មនុស្សគ្រប់ជំនាន់ទាំងអស់អាចចូលរួមនៅក្នុងដំណើរការនេះតាមរយៈការផ្តល់ជាការរៀបរាប់រឿងរ៉ាវផ្ទាល់ខ្លួន ឬ ចូលរួមនៅក្នុងវេទិកាពិភាក្សា ។ តាមរយៈការពង្រីកពេលវេលាដែលធ្វើឲ្យមានការចែករំលែកបទពិសោធន៍នោះពាក្យថា "ជនរងគ្រោះ" និង "ជនដៃដល់" អាចនឹងត្រូវបានយល់ក្នុងន័យផ្សេង ។ យោងតាមអត្ថបទរបស់លោក នូវង់ហ្គូ ពាក្យទាំងពីរខាងលើនេះអាចក្លាយជាល័ក្ខខ័ណ្ឌបណ្តោះអាសន្នដែលបុគ្គលម្នាក់អាចក្លាយជាសមាជិកណាមួយនៃក្រុមទាំងពីរនេះ ។ ជនរងគ្រោះនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យប្រហែលជាបានសម្លាប់មនុស្សដើម្បីសងសឹក ប៉ុន្តែតាមរយៈបង្កើតឲ្យមានឱកាសសម្រាប់ចែករំលែកបទពិសោធន៍ បទពិសោធន៍ខុសប្លែកគ្នាទាំងនេះក៏ត្រូវបានលាតត្រដាង ។

នៅក្នុងបរិបទជាច្រើនបែប ការស្វែងរកការពិត និងការបង្កើតជារឿងប្រវត្តិសាស្ត្រមួយនឹងប្រឈមមុខនឹងបញ្ហាមួយចំនួនជាមិនខាន ។ ឧបសគ្គធំមួយនៅក្នុងដំណើរការនេះគឺទាក់ទងនឹងការធានាឲ្យបាននូវការចូលរួម និងការផ្តល់រឿងរ៉ាវផ្ទាល់ខ្លួនពីសំណាក់អតីតជនដៃដល់ ។ មធ្យោបាយសម្រាប់ដោះស្រាយបញ្ហានេះគឺថាយើងត្រូវធានាជនដៃដល់ថា ប្រសិនបើអ្នកទាំងនោះចែករំលែករឿងរ៉ាវរបស់ខ្លួននោះ ពួកគេនឹងមិនត្រូវបានកាត់ទោសសម្រាប់ការប្រព្រឹត្តកន្លងមកឡើយ ។វេទិកាពិភាក្សាត្រូវតែរៀបចំឡើងដោយជម្រុញឲ្យមានបរិយាកាសល្អដើម្បីឲ្យអ្នកចូលរួមទាំងអស់ធ្វើការចែករំលែក និងរៀនសូត្រពីគ្នាទៅវិញទៅមកជាជាងធ្វើការពង្រីងឲ្យមានការបែងចែកប្រភេទអ្នកចូលរួម ។ គម្រូនេះអាចមានលក្ខណៈស្រដៀងយុត្តិធម៌តាមរយៈការផ្សះផ្សារតាមផ្លូវច្បាប់ ហើយអាចជួយជម្រុញឲ្យមានអនាគតដែលពោរពេញទៅដោយសន្តិភាព និងស្ពាបនាទំនាក់ទំនងរបស់សង្គមសារជាថ្មី ។ សំខាន់ជាងនេះ ការស្រាវជ្រាវបន្ថែមគួរតែត្រូវផ្តួចផ្តើមឡើងដោយកំណត់ថាតើប្រជាជនកម្ពុជាគិតថាការចូលរួមពីជនដៃដល់គួរតែត្រូវបានដោះស្រាយយ៉ាងដូចម្តេច ។ ចំណែកការចូលរួមពីសំណាក់មេដឹកនាំសាសនានឹងក្លាយជាផ្នែកមួយដ៏សំខាន់ក្នុងការធានាឲ្យមានការចូលរួមពីសំណាក់ជនដៃដល់ ។

បញ្ហាមួយទៀតគឺទាក់ទងនិងការបង្កើតជាក្រុមចងក្រងនិងវិភាគព័ត៌មាន ។ ក្រៅពីការចងក្រងជារឿងរ៉ាវផ្សេងៗ គម្រោងនេះត្រូវតែឆ្លើយនឹងសំណួរថា "ហេតុអ្វី" បានជាការសម្លាប់ដែលកើតមាន

ឡើងត្រូវចាត់ទុកថាមានសារសំខាន់សម្រាប់ប្រជាជនកម្ពុជាទូទៅ ។ ស្របពេលដែលចម្លើយសម្រាប់សំណួរនេះ នឹងទទួលបានពីសក្ខីកម្មរបស់ជនដែដល់ និងជនរងគ្រោះនោះ អ្នកប្រាជ្ញដែលមានការយល់ដឹងជ្រាលជ្រៅមានឯករាជ្យនិងអព្យាក្រឹត្យ ក៏ត្រូវតែអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រឹងប្រែងវិភាគ និងចងក្រងទិន្នន័យដើម្បីរកឲ្យឃើញនូវការពិតរបស់ប្រវត្តិសាស្ត្រនេះដែរ ។

បញ្ហាមួយទៀតដែលអាចក្លាយជាកត្តាជោគជ័យ សម្រាប់ការដោះស្រាយបញ្ហាសំខាន់ផ្សេងៗទៀត គឺថាប្រជាជនកម្ពុជាអាចគិតថាបញ្ហាជម្លោះដីធ្លី ការទទួលបានការអប់រំ និងបញ្ហាសុខភាពជាបញ្ហាសំខាន់នៅក្នុងជីវិតរបស់គេហើយអាចនឹងមិនចង់ចូលរួមនៅក្នុងដំណើរការរបស់គណៈកម្មការស្វែងរកការពិតនេះ ។ សម្រាប់ប្រជាជនកម្ពុជាមួយចំនួនដូចជាប្រជាជនដែលរស់នៅតាមព្រំដែនថៃជាដើម ការបញ្ចប់ទៅនៃរបបខ្មែរក្រហមបានរកយុត្តិធម៌តិចតួចណាស់ឲ្យពួកគេ ។ ការអាក់អន់ចិត្ត និងការខឹងសម្បាទាំងអស់នេះអាចយកមកប្រើប្រាស់ ជាកត្តាជោគជ័យមួយដើម្បីធ្វើឲ្យប្រជាជនទាំងអស់រួបរួមគ្នាហើយបណ្តុះបណ្តាលឲ្យមានជាពលរដ្ឋចេះទាមទាររកយុត្តិធម៌បន្ថែមទៀត ។ បើទោះបីជាមិនមានចម្លើយដ៏ងាយស្រួលថាតើគណៈកម្មាការស្វែងរកការពិតអាចនឹងដោះស្រាយនឹងតម្រូវការទាំងអស់នេះក៏ដោយ ក៏ការបង្កើតជាយន្តការដែលមានលក្ខណៈច្នៃប្រឌិតថ្មីនេះ អាចនឹងធ្វើឲ្យមានការងាយស្រួយក្នុងការដោះស្រាយ បញ្ហាសំខាន់ៗទាំងអស់នេះបាន ។

ការព្រួយបារម្ភដំបូងបង្អស់ដែលត្រូវចងចាំក្នុងអំឡុងដំណើរការរៀបចំនិងអនុវត្ត គឺទាក់ទងនិងការគ្រប់គ្រងលើការរំពឹងចង់បានរបស់បុគ្គលផ្សេងៗ ។ ប្រជាជនទាំងអស់ត្រូវយល់ពីគោលដៅរបស់គម្រោងគណៈកម្មការនេះដោយគ្មានការរំពឹងទុកថានឹងទទួលបានសំណងថ្លៃខូចខាត ដំណើរការកាត់ទោសលើជនសង្ស័យបន្ថែមទៀតឬយុត្តិធម៌ដល់បុគ្គលនីមួយៗទេ ។ ការរៀបចំសកម្មភាពនៅតាមសហគមន៍នីមួយៗស្តីការរំពឹងទុកខាងលើគឺពិតជាមានសារសំខាន់សម្រាប់ជោគជ័យនៃកិច្ចប្រឹងប្រែងនេះ ។ មុននឹងគម្រោងនេះចាប់ផ្តើមដំណើរការនៅតាមសហគមន៍ អ្នកដែលចូលរួមនៅក្នុងការអនុវត្តក្នុងតំបន់ត្រូវតែធ្វើការពន្យល់ពីព្រំដែនកំណត់នៃការអាចធ្វើបានរបស់គម្រោង និងការជាប់ពាក់ព័ន្ធនឹងការចូលរួមនេះ ។ នៅក្នុងអំឡុងពេលប្រមូលសក្ខីកម្មឬរៀបចំព្រឹត្តិការណ៍ពិភាក្សា ការក្រើនរំឭកជាបន្តបន្ទាប់ត្រូវតែធ្វើឡើងក្នុងទម្រង់ជាឯកសារ ការប្រកាសជាសម្លេង និងការធ្វើបទសម្ភាសន៍ ឬការទាក់ទងដោយផ្ទាល់នឹងប្រជាជន ដើម្បីឲ្យអ្នកទាំងអស់នេះយល់ថាយន្តការនេះគឺជាឱកាសតែមួយគត់ដែលប្រជាជនទាំងអស់អាចចែករំលែក និងនិយាយពីបទពិសោធន៍របស់ខ្លួននិងដើម្បីឲ្យសេចក្តីរំពឹងចង់បានរបស់អ្នកទាំងអស់នេះទទួលបានការតំណាងពីដំណើរការនេះវិញ ។

ដោយសារតែការនិយាយ ឬសរសេរពីបទពិសោធន៍ដ៏លំបាកបែបនេះអាចនឹងបង្កជាបញ្ហាផ្លូវចិត្តដល់អ្នកចូលរួមធនធានផ្សេងៗសម្រាប់ការជួយផ្គត់ផ្គង់បញ្ហានេះចាំបាច់ត្រូវតែមាន ដូចជាព័ត៌មានទំនាក់ទំនងអ្នកជំនាញខាងចិត្តសាស្ត្រជាដើម ។ វាគួរតែមានការសហការជាដៃគូរពីសំណាក់អង្គការសុខភាពផ្លូវចិត្តដើម្បីធានាឲ្យមានវត្តមានចូលរួមពីអ្នកជំនាញខាងផ្លូវចិត្តនៅតាមសហគមន៍ក្នុងអំឡុងនិងក្រោយពេលប្រមូលយកសក្ខីភាពជាពិសេសគឺនៅពេលដែលព្រឹត្តិការណ៍ពិភាក្សាជាសាធារណៈនេះត្រូវបានរៀបចំឡើង ។ មេដឹកនាំសាសនាក៏អាចផ្តល់ជំនួយខាងផ្នែកសាសនា និងការគាំទ្រដោយផ្អែកលើការជឿជាក់បានដែរ ។

ខណៈពេលគ្រូបង្រៀនទាំងអស់ត្រូវបានបណ្តុះបណ្តាល ដើម្បីបំពេញកិច្ចការសម្រួលទាំងអស់នេះនៅក្នុង ដំណើរបេសកកម្មរបស់ខ្លួន នោះគម្រោងនេះនឹងចំណាយថវិកាសមល្មមតែប៉ុណ្ណោះ ។ ប៉ុន្តែវគ្គបណ្តុះបណ្តាលនឹងទាមទារធនធានច្រើន ។ បន្ថែមលើនេះ តាមរយៈការប្រើប្រាស់គ្រូបង្រៀនក្នុងស្រុកនោះ ការទាក់ទាញឲ្យមានការចូលរួមពីសំណាក់ប្រជាជនខ្មែរក្រៅប្រទេសនឹងមិនអាចសម្រេចបាននោះទេ ។ ដោយសារតែប្រជាជនដែលបានចាកចេញពីប្រទេសកម្ពុជាក្នុងកំឡុង និងក្រោយទសវត្សរ៍៧០ ក៏មានរឿងរ៉ាវសំខាន់ៗដើម្បីចូលរួមនៅក្នុងការរកឃើញនូវការពិត របស់ប្រវត្តិសាស្ត្រនេះ នោះគណៈកម្មាធិការអប់រំគួរតែត្រូវបានបង្កើតឡើង នៅពេលអនាគតដើម្បីធានាថាការប្រមូលចងក្រងរឿងរ៉ាវរបស់ប្រជាជនកម្ពុជាក៏អាចធ្វើទៅបាននៅខាងក្រៅប្រទេសកម្ពុជាដែរ ។ នៅក្នុងករណីរបស់ប្រទេសសៀរ៉ាឡេអូន ក្រុមអ្នកតំណាងគណៈកម្មាការដូចជាអង្គការក្រៅរដ្ឋាភិបាលនៅសហរដ្ឋអាមេរិកបានចូលរួមប្រមូលយករឿងរ៉ាវរបស់ប្រជាជន សៀរ៉ា ឡេអូន ដែលរស់នៅក្រៅប្រទេសដែរ ។ អ្នកដែលបានចូលរួមនៅក្នុងការបង្កើតដំណើរការនេះអាចជួយផ្តល់ជាការណែនាំ ដើម្បីសម្រេចកិច្ចការនេះជាមួយនឹង ប្រជាជនកម្ពុជាដែលរស់នៅក្រៅប្រទេស ។

អណត្តិ និងគោលដៅនៃការអនុវត្តរបស់គម្រោងនេះត្រូវតែមានលក្ខណៈច្បាស់លាស់ ។ ក្រុមការងាររបស់គម្រោងនេះត្រូវបានគេហៅថា“គណៈកម្មាការផ្សះផ្សារ និងស្វែងរកការពិត” ។ យ៉ាងណាមិញឈ្មោះនេះបង្កជាការយល់ច្រឡំពីគោលដៅជាច្រើនរបស់គម្រោងនេះ និងធ្វើឲ្យមានការរំពឹងចង់បានខ្ពស់ពីដំណើរការផ្សះផ្សាមួយ ដែលដំណើរការនេះមិនអាចបំពេញទៅតាមការរំពឹងចង់បានទាំងអស់នេះបានឡើយ ។ ប្រជាជនខ្លះនៅក្នុងប្រទេសកម្ពុជាបានផ្សះផ្សារជាមួយនឹងបទពិសោធន៍របស់ខ្លួននិងជាមួយអ្នកដទៃទៀតដែលធ្វើបាបខ្លួនឬដែលគេបានធ្វើបាប ។ ចំណែកប្រជាជនដទៃទៀតវិញនឹងមិនអាចរកឃើញការផ្សះផ្សាឡើង បើទោះបីជាដំណើរការផ្សះផ្សា និងស្វែងរកការពិតនេះអាចជួយដោះស្រាយបញ្ហាពីអតីតកាលបានក៏ដោយ ។ សម្រាប់ប្រទេសកម្ពុជានៅក្នុងពេលនេះតម្រូវការចាំបាច់

នោះគឺត្រូវតែកំណត់ពិការពិត និងបង្កើតជារឿងរ៉ាវមួយដែលជួយនាំយកបទពិសោធន៍របស់បុគ្គលម្នាក់ៗដាក់ចូលទៅក្នុងបរិបទធំមួយ ហើយឆ្លើយតបទៅនឹងសំណួរដែលថា «ហេតុអ្វី» បានជាខ្មែរក្រហមប្រព្រឹត្តអំពើសាហាវឃោរឃៅបែបនេះ ។ សម្រាប់ប្រជាជនកម្ពុជាខ្លះ ដំណើរការផ្តល់សក្ខីភាព និងចូលរួមនៅក្នុងវេទិកាពិភាក្សាសាធារណៈទាំងនេះអាចជួយផ្តល់ការផ្សះផ្សារដល់គេបាន ។សម្រាប់ប្រជាជនដទៃទៀតវិញ ចំណេះដឹងគឺជាអត្ថប្រយោជន៍ដ៏ធំដែលពួកគេអាចទទួលបាន ។ ដើម្បីធ្វើឲ្យគម្រោងស្វែងរកការពិត និងចងក្រងអតីតកាលនេះទទួលបានជោគជ័យ និងឋិតថេរនោះ អណាត្តិបំពេញការងារដោយយកចិត្តទុកដាក់បំផុតមួយអាចនឹងនាំមកនូវលទ្ធផលដ៏ល្អបំផុតសម្រាប់ការស្វែងរកការពិតពីប្រវត្តិសាស្ត្រនេះ ។

ខែតុលា ឆ្នាំ២០១០

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖

លោក អេង កុកថៃ ៖ truthkokthay@dccam.org